# កម្ពុជា - ដើមអំពៅ -ពលកម្មកុមារ

មានសេចក្តីរាយការណ៍ជាច្រើននិយាយអំពីកុមារ ពីអាយុ ៥ ទៅ ១៧ ឆ្នាំ ផលិតដើមអំពៅ នៅក្នុងប្រទេសកម្ពុជា។ ពលកម្មកុមារ ក្នុងផ្នែកដើមអំពៅ កើតមានឡើង ទាំងនៅក្នុងការច្បារដាំដើមអំពៅដើម្បីពាណិជកម្ម និង នៅក្នុងកសិដ្ឋានតូចតាច។ ក្មេងកុមារ មកពីគ្រួសារបាត់បង់ដីធ្លី ដោយសារសម្បទានទៅឲ្យក្រុមហ៊ុនដើមអំពៅ ទទួលរងគ្រោះជាពិសេសទៅនឹងការកេងប្រវ័ញ្ចខាងពលកម្ម នៅលើទីកន្លែងចំការដំណាំ។ យោងតាមអង្គការអន្តរជាតិ ឬ អង្គការមិនមែនរដ្ឋាភិបាល និងសេចក្តីរាយការណ៍របស់បណ្តាញពត៌មាន ពលកម្មកុមារនៅក្នុងប្រទេសកម្ពុជា ផ្នែកដើមអំពៅ មានភាពធំធេង គួរឲ្យព្រួយបារម្ភខ្លាំង ដោយគេឃើញមានសេចក្តីរាយការណ៍ជាច្រើននិយាយអំពីគ្រោះថ្នាក់ ទូទាំងប្រទេស រាប់ទាំង សេចក្តីរាយការណ៍និយាយអំពី កុមារច្រើនរយនាក់ កំពុងគាស់កាប់ដើមអំពៅក្នុងចំការ នៃខេត្តកោះកុង។ កុមារធ្វើការដោយលំបាក នៅលើចំការអំពៅ ប្រើពេលច្រើនម៉ោងហើយ យូរ នៅក្រោមកំដៅថ្ងៃចែស បណ្តាលឲ្យមានការលំបាកដល់ការដកដង្ហើម មានអាការៈឈឺក្បាល វិលមុខ។ កុមារធ្វើការក្នុងផ្នែកនេះ បានបំពេញភារៈកិច្ចប្រកបដោយគ្រោះថ្នាក់ ដូចជាលើកកងទម្ងន់ធ្ងន់ៗ នៃបាច់អំពៅ ប្រើឧបករណ៍គ្រោះថ្នាក់ បាញ់ថ្នាំគីមីពុល ដើម្បីសម្លាប់សត្វល្អិត។ កុមារជាច្រើនបានរងរបួស នៅពេលធ្វើការ ដូចជារបួសស្បែកក្លាយ ដោយសារ មុតស្លឹកអំពៅស្រួច ឬ កាំបិត។